<u>**សូមគោរពជូន**</u>

**ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

<u>**កម្មវត្ថុ:**</u>សំណើសុំទទួលស្គាល់សិទ្ធិផ្តាច់មុខលើការនាំចូល និង ចែកចាយផលិតផល យានយន្ត និង គ្រឿងបន្លាស់ គ្រប់ប្រភេទ ម៉ាក **LD DR** នៅក្នុង ព្រះរាជាណាចក្រកម្ពុជា ។

<u>**យោង:**</u> - វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជកម្ម លេខ ៧៣០ ពណ.ចបព ចុះថ្ងៃ ទី ២៨ ខែ ធ្នូ ឆ្នាំ ២០

- វិញ្ញាបនប័ត្រចុះបញ្ជីពាណិជ្ជសញ្ញាម៉ាក **LD DR** លេខចុះបញ្ជី ១១៧ ចុះថ្ងៃ ទី ២០ ខែ សីហា ឆ្នាំ ១៩៩២

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើ យើងខ្ញុំសូមជំរាបជូនឯកឧត្តមទេសរដ្ឋមន្ត្រីមេត្តាផ្តល់នូវលិខិតទទួលស្គាល់សិទ្ធិផ្តាច់មុខលើការនាំចូល និង ចែកចាយផលិតផល យានយន្ត និង គ្រឿងបន្លាស់គ្រប់ប្រភេទ នៅក្នុងព្រះរាជាណាចក្រកម្ពុជា និង បានតំកល់ការពារពាណិជ្ជសញ្ញាខាងលើនេះនៅនាយកដ្ឋានកម្មសិទ្ធិបញ្ញា ក្រសួង ពាណិជ្ជកម្មរួចហើយ ។

យោងតាមសភាពការណ៍ជាក់ស្តែង និង ដើម្បីការពារផលវិបាកទាំងឡាយដែលអាចកើតមានឡើងចំពោះក្រុមហ៊ុនយើងខ្ញុំផ្ទាល់ក្នុងការរំលោភសិទ្ធិផ្តាច់មុខពីសំណាក់ក្រុមហ៊ុន និងពាណិជ្ជករដ៏ទៃទៀត ដែលមានបំណងប្រកួតប្រជែង មិនស្មោះត្រង់នោះ យើងខ្ញុំសូមឯកឧត្តមទេសរដ្ឋមន្ត្រីមេត្តាចេញលិខិតទទួលស្គាល់នូវសិទ្ធិផ្តាច់មុខស្របច្បាប់ដល់ក្រុមហ៊ុនយើងខ្ញុំ និងជួយមានវិធានការណ៍តាមផ្លូវច្បាប់ក្នុងករណីមានការរំលោភបំពានទាំងឡាយដែលអាចកើតមានឡើងជាយថាហេតុ ដែលនាំអោយប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ក្រុមហ៊ុនយើងខ្ញុំ ក្នុងការធ្វើអាជីវកម្មនូវផលិតផលខាងលើ ។

សូមឯកឧត្តមទេសរដ្ឋមន្ត្រីមេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីយើងខ្ញុំ ។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ ២០១៤

**ហត្ថលេខា និងត្រា**